

## ជំពូកទី៣

# គោលការណ៍ណែនាំសំរាប់ការបង្រៀនភាសា

កុមារម្នាក់ដែលថ្លង់ ឬមិនអាចស្ដាប់ឮល្អរៀនប្រាស្រ័យទាក់ទងដោយការមើលឃើញ។ ក្មេងនេះមិនរៀនពាក្យដូចកុមារដទៃទៀតដោយគ្រាន់តែស្ដាប់មនុស្សនិយាយគ្នានោះទេ។ កុមារថ្លង់ ឬមិនអាចស្ដាប់ឮល្អត្រូវការពេលច្រើន និងជួយបំប៉នបន្ថែមដើម្បីរៀនភាសាមួយ ទោះជាយកការមើល និងការស្ដាប់មនុស្សនិយាយគ្នា ឬក៏មើលពួកគេធ្វើសញ្ញាក្ដី។ កុមារថ្លង់ ឬមិនអាចស្ដាប់ឮល្អ អាចចាប់ផ្ដើមផ្ដោតការយកចិត្តទុកដាក់លើពាក្យសរសេរបានលឿនជាងកុមារផ្សេងៗទៀត។ នៅពេលបានឃើញពាក្យសរសេរ ដូចជាឈ្មោះរបស់ខ្លួន ក្មេងថ្លង់អាចធ្វើការផ្សារភ្ជាប់រវាងពាក្យ និងន័យរបស់វាបាន។

គោលការណ៍ណែនាំនៅក្នុងជំពូកនេះ អាចជួយបង្កភាពងាយស្រួលសំរាប់ឪពុកម្ដាយ និងមនុស្សផ្សេងៗទៀតក្នុងការបង្រៀនរបៀបប្រើភាសាដល់កុមារថ្លង់។ សូមព្យាយាមប្រើគោលការណ៍ណែនាំទាំងនេះ ខណៈពេលអនុវត្តសកម្មភាពនៅក្នុងសៀវភៅនេះ។

## ប្រាស្រ័យទាក់ទងឱ្យច្រើនតាមតែអ្នកអាចធ្វើបាន

ការជួយកុមារថ្លង់រៀនភាសា គឺជាការសំខាន់បំផុតដែលឪពុកម្ដាយ និងមនុស្សឯទៀតអាចធ្វើបាន។ ទោះបីជាទូទៅមនុស្សទាំងឡាយមិននិយាយរកកុមារ នៅពេលពួកគេបំពេញការងាររបស់ខ្លួនក៏ដោយ តែកូនអ្នកត្រូវការឱ្យមនុស្សគ្រប់គ្នាព្យាយាមនិយាយរកខ្លួនបន្ថែមទៀត។ ការប្រាស្រ័យទាក់ទង គឺជាវិធីតែមួយគត់ដែលកូនអ្នកនឹងរៀនចេះ។

ជួនកាលឪពុកម្ដាយប្រហែលមានអារម្មណ៍អៀនខ្មាស ដោយសារកូនមិនអាចស្ដាប់ឮល្អ ឬកុមារអាចត្រូវបានការពារហួសហេតុពេក។ ប៉ុន្តែកុមារត្រូវការចូលរួមចំណែកក្នុងសកម្មភាពនៃគ្រួសារខ្លួន។ ការមិនឱ្យកុមារចូលរួមក្នុងសកម្មភាពនឹងធ្វើឱ្យកុមារមិនបានរៀនសូត្រពីអ្វីៗទាំងអស់។

នៅពេលថ្ងៃ សូមរកមើលឱកាសប្រាស្រ័យទាក់ទងឱ្យបានច្រើនជាមួយកូនអ្នក។ អ្នកត្រូវឱ្យកូនចូលរួមក្នុងសកម្មភាពផ្សេងៗជាមួយមនុស្សឯទៀត ធ្វើដូច្នេះកូនអាចរៀនទម្លាប់ខ្លួន មើលឃើញ និងស្ដាប់ឮមនុស្សដទៃទៀតប្រាស្រ័យទាក់ទងគ្នា។ លើកទឹកចិត្តដល់ក្រុមគ្រួសារទាំងមូល បងប្អូនប្រុស ស្រី យាយ តា និងសាច់ញាតិឱ្យធ្វើដូច្នេះផងដែរ។




**កុមារត្រូវចូលរួមចំណែកក្នុងសកម្មភាពនៃគ្រួសាររបស់ខ្លួន។**

## បញ្ចូលសកម្មភាពទៅក្នុងការរស់នៅប្រចាំថ្ងៃនៃក្រុមគ្រួសារ

វាជាការសំខាន់ក្នុងការគិតគូរពីរបៀបគាំទ្រការអភិវឌ្ឍរបស់កូនអ្នក នៅក្នុងវិធីទាំងឡាយណាដែលអ្នកគិតថាមានប្រយោជន៏សំរាប់ក្រុមគ្រួសារ។ សកម្មភាពមួយចំនួនក្នុងសៀវភៅនេះ ត្រូវចំណាយពេលច្រើនបន្តិចក្នុងការអនុវត្ត ឬអាចធ្វើឱ្យផ្លាស់ប្តូរវិធីដែលអ្នកមានទម្លាប់ធ្វើពីមុន។




កូនអ្នកអាចរៀនបានល្អប្រសើរ នៅពេលការបង្រៀនក្លាយជាចំណែកមួយនៅក្នុងសកម្មភាពប្រចាំថ្ងៃ។

- និយាយ ឬធ្វើសញ្ញាទៅរកកូន ពេលអ្នកធ្វើសកម្មភាពជាមួយគ្នា ដូចជា ការហូបចុក ងូតទឹក ផ្លាស់ខោអាវ និងធ្វើអ្វីៗផ្សេងទៀត។ ទាំងនេះជាពេលវេលាល្អសំរាប់និយាយ និងធ្វើសញ្ញា ពីព្រោះអ្នកនៅជិតស្និទ្ធនឹងកូន ហើយតាមធម្មតាកូនតែងយកចិត្តទុកដាក់ចំពោះអ្នក។




ក្នុងពេលនិយាយពីវត្ថុនីមួយៗ អ្នកប្រើសញ្ញា ឬពាក្យដែលមានន័យដូចវត្ថុនោះនៅរាល់ៗពេល ដើម្បីរៀបរាប់នូវអ្វីដែលអ្នកកំពុងធ្វើ។ ប្រការនេះ ជួយឱ្យកូនចេះន័យរបស់សញ្ញា និងពាក្យ ហើយជួយកូនឱ្យចេះប្រើសញ្ញា និងពាក្យនានា (សូមអានជំពូកទី4 ត្រង់ទំព័រ37 ដល់ 46)។

**ម្តាយរបស់*លីហ្វភ*ប្រើសញ្ញាប្រចាំផ្ទះទាក់ទងជាមួយកូន។**

- នៅពេលអ្នកធ្វើការ ឱ្យកូននៅក្បែរឱ្យបានច្រើនតាមដែលអាចធ្វើបាន។ បញ្ចេញមតិខ្លីៗឱ្យបានច្រើនពីអ្វីដែលអ្នកកំពុងធ្វើ។




**ម្តាយរបស់*កេសភ*ប្រើភាសាសញ្ញាធ្វើទំនាក់ទំនងជាមួយកូន។**

- ចូរនិយាយ និងធ្វើសញ្ញាអ្វីដែលអ្នកគិតថា កូនមើលឃើញ ធ្វើ និងមានអារម្មណ៍ទៅលើវា ធ្វើខ្លួនអ្នកហាក់បីដូចជាកូនអញ្ចឹង ។




**បងជីដូនមួយរបស់ *តាវ៉ាដ* ប្រើពាក្យ និងសំដែងទឹកមុខ ដើម្បីប្រាស្រ័យទាក់ទងជាមួយ *តាវ៉ាដ*។**

- ធ្វើតាមការចាប់អារម្មណ៍របស់កុមារ ។ ចូរធ្វើសកម្មភាពដោយប្រើវត្ថុណាដែលកូនចាប់អារម្មណ៍ ។




## ភាពប្រាកដនិយមសមហេតុផល

- ព្យាយាមលៃលកពេលរបស់អ្នក និងមនុស្សឯទៀតយ៉ាងណាឱ្យសមល្មមអាចចំណាយធ្វើសកម្មភាពជាមួយកូន ។
- ព្យាយាមយកសកម្មភាពទាំងឡាយណាដែលចំណាយពេលតិច និងងាយសម្រួលទៅក្នុងសកម្មភាពប្រចាំថ្ងៃរបស់អ្នក ។




- ព្យាយាមបំបែកការងារធំៗ ទៅជាជំហានតូចៗដែលងាយអនុវត្តតាមដំណាក់ៗ ។ អ្នកនឹងបានឃើញការរីកចំរើនតាមវិធីនេះ និងមិនធ្លាក់ទឹកចិត្ត ។



## មនុស្សជាច្រើនអាចជួយធ្វើសកម្មភាពទាំងនេះ

ទោះជាយ៉ាងណាក៏ដោយ កុមារត្រូវការការយកចិត្តទុកដាក់ និងសេចក្ដីស្រឡាញ់ពីឪពុកម្ដាយទាំងពីររបស់ខ្លួន ឪពុកម្ដាយមិនគួរជាគ្រូបង្រៀនតែម្នាក់របស់កូននោះទេ។ អនុញ្ញាតឱ្យមិត្តភ័ក្តិ ញាតិជិតខាង និងសមាជិកក្នុងក្រុមគ្រួសារផ្សេងទៀតជួយបង្រៀនក្មេងផងដែរ។ អ្នកត្រូវរាប់អាន ស្គាល់មនុស្សថ្លង់ពេញវ័យដែលចេះភាសាសញ្ញា។ វាជាការសំខាន់សំរាប់កុមារថ្លង់ ឬមិនអាចស្ដាប់ឮល្អដែលមានមនុស្សជាច្រើនធ្វើសកម្មភាពជាមួយគេ ពីព្រោះ :-

- វានឹងជួយកុមារឱ្យចេះប្រាស្រ័យទាក់ទងជាមួយមនុស្សជាច្រើន រួមទាំងមនុស្សថ្លង់ផ្សេងៗទៀត។
- កុមារនឹងរៀនសម្របខ្លួនជាមួយមនុស្សប្លែកៗពីគ្នា។
- មនុស្សផ្សេងៗទៀតនឹងរៀនរបៀបឆ្លើយឆ្លងគ្នាទៅវិញទៅមកជាមួយមនុស្សថ្លង់។




**ឪពុកម្ដាយដែលមានកូនថ្លង់ ឬមិនអាចស្ដាប់ឮអាចធ្វើការរួមគ្នាដើម្បីដោះស្រាយបញ្ហា** **( សូមអានទំព័រ184)**

មនុស្សមួយចំនួន ទោះបីគេជាសមាជិកជិតស្និទ្ធនឹងក្រុមគ្រួសារក៏ដោយ ពួកគេអាចមិនចង់ចំណាយពេលជាមួយកុមារថ្លង់ទេ។ ទោះបីជាមនុស្សមួយចំនួនទៀតមានចិត្តចង់ជួយ ក៏មិនដឹងជួយដោយរបៀបណា។ អ្នកអាចជួយពួកគេសិក្សាអំពីភាពថ្លង់ និងការរស់នៅរបស់មនុស្សថ្លង់ ដែលមានការលំបាកជាច្រើនក្នុងការរៀនភាសា។ ពួកគេអាចមានអារម្មណ៍ធូរស្រាលក្នុងចិត្ត បើសិនជាពួកគេដឹងនូវអ្វីដែលត្រូវធ្វើ។

អ្នកត្រូវចេះចែករំលែកនូវអ្វីដែលអ្នកបានរៀនអំពីបញ្ហាការស្ដាប់ សកម្មភាពដែលអ្នកនិងកូនកំពុងធ្វើ ព្រមទាំងហេតុផលសំរាប់ធ្វើសកម្មភាពទាំងនេះ។

## និយាយជាមួយក្រុមគ្រួសាររបស់អ្នក

មនុស្សក្នុងគ្រួសារទាំងអស់ សុទ្ធតែមានភារកិច្ចក្នុងជីវិតរស់នៅរបស់កុមារ។ មនុស្សទាំងអស់ដែលមានភារកិច្ចថែទាំកុមារ អាចមានគំនិតខុសពីគ្នាលើវិធីដែលល្អបំផុតសំរាប់ចិញ្ចឹម និងជួយក្មេងនោះ ជាពិសេសក្មេងមានតម្រូវការពិសេស។ វាជាការសំខាន់ណាស់សំរាប់អ្នកទាំងអស់ដែលមានភារកិច្ចថែទាំកុមារនោះ រកពេលជំនុំគ្នានិងយល់គំនិតគ្នាទៅវិញទៅមក។




បើនរណាម្នាក់ ក្នុងចំណោមអ្នកទាំងអស់ អស់កម្លាំង ឬធ្លាក់ទឹកចិត្ត អ្នកផ្សេងទៀតអាចជួយបាន។

## ស្នើសុំឱ្យមនុស្សឯទៀតជួយសំរាលទុក្ខធុរៈដល់អ្នក

ឪពុកម្តាយអាចសុំឱ្យសមាជិកឯទៀតក្នុងសហគមន៍ ឬអ្នកជិតខាងជួយមើលថែទាំកុមារថ្លង់។

មនុស្សស្តាប់ឮដែលចេះប្រើភាសាសញ្ញាអាចជួយអ្នកប្រាស្រ័យទាក់ទងជាមួយមនុស្សថ្លង់ពេញវ័យ បើសិនជាអ្នកមិនចេះភាសាសញ្ញា។




អ្នកត្រូវជួបប្រជុំជាមួយមនុសថ្លង់ក្នុងសហគមន៍របស់អ្នក។ មនុស្សថ្លង់ពេញវ័យចងចាំនូវអារម្មណ៍ទាំងឡាយ កាលគេនៅជាក្មេងថ្លង់។ ពួកគេប្រហែលជាសប្បាយចិត្តនឹងជួយក្រុមគ្រួសារ និងកូនរបស់អ្នក។

អ្នកត្រូវជួបពិភាក្សានឹងភ្នាក់ងារសុខាភិបាល ឬគ្រូបង្រៀននៅសាលា ឬបុគ្គលដែលបង្រៀនកុមារថ្លង់។ ប្រការនេះមានប្រយោជន៍ជាពិសេសក្នុងការជួយកូន បើសិនជាកូនអ្នកហាក់ដូចជាមិនចេះបំណិនថ្មីៗនៅរយៈពេលពីរបីខែក្រោយមក។



### កុមារអាចជួយរួមចំណែកក្នុងសកម្មភាពទាំងនេះ

កុមារអាចជាអ្នកជួយដ៏មានប្រយោជន៍បំផុត ។ តាមធម្មតា បងប្អូនប្រុសស្រី និងមិត្តភ័ក្តិឯទៀតរបស់កុមារថ្លង់ អាចរៀនចេះភាសាសញ្ញាយ៉ាងឆាប់រហ័ស ។ ឱ្យកុមាររួមចំណែកក្នុងសកម្មភាពទាំងនេះ ឱ្យបានច្រើនតាមដែលអាចធ្វើបាន ។

កុមារតូចៗអាចចូលរួមក្នុងសកម្មភាពនានា និងកុមារធំៗអាចធ្វើជាគ្រូបង្រៀន បើសិនជាអ្នកណែនាំបង្ហាញរបៀបដែលត្រូវធ្វើដល់ពួកគេ ។ កុមារធំៗក៏អាចបង្រៀនកុមារថ្លង់ពីបំណិនផ្សេងៗ និងឱ្យកុមារថ្លង់ចូលរួមលេងកំសាន្តជាមួយពួកគេ ។ ប្រការនេះ នឹងជួយកុមារថ្លង់ឱ្យមានមិត្តភ័ក្តិ និងរៀនសម្របចិត្តជាមួយមនុស្សឯទៀត ។ ប្រការនេះក៏អាចជួយកុមារស្តាប់ឮរៀនអំពីភាពថ្លង់ និងរបៀបប្រាស្រ័យទាក់ទងជាមួយកុមារថ្លង់ផងដែរ ។



**តាមនិស្ស័យធម្មជាតិ ជាញឹកញាប់ កុមារធំៗច្រើនតាំងខ្លួនជាគ្រូបង្រៀន និងរីករាយធ្វើសកម្មភាពទាំងនេះ ជាមួយកុមារតូចៗជាងខ្លួន ។**

## យោបល់សំរាប់ជួយដល់ការរៀនសូត្ររបស់កូនអ្នក

### ទុកឱ្យកូនធ្វើជាអ្នកនាំមុខ

កុមារតែងបង្ហាញឆន្ទៈចង់រៀនសូត្រ នៅពេលពួកគេធ្វើអ្វីមួយដែលខ្លួនពេញចិត្ត ។ បើកូនអ្នកចាប់អារម្មណ៍លើអ្វីមួយ ឬចូលចិត្តលេងនឹងល្បែងពិសេសណាមួយ ចូរធ្វើឱ្យឱកាសនោះទៅជាពេលជួយកូនឱ្យចេះប្រាស្រ័យទាក់ទង ឬរៀនសូត្រ ។




ទុកឱ្យកូនធ្វើជាអ្នកនាំមុខ ។ វានឹងរក្សាចំណាប់អារម្មណ៍ និងភាពជាអ្នកនាំមុខនេះ ជួយកូនឱ្យឃើញថា ការសំរេចចិត្តរបស់ខ្លួនគឺជាការសំខាន់ ។ កូននឹងដឹងថា ខ្លួនមានអំណាចត្រួតត្រា លើអ្វីៗមួយចំនួនដែលកើតឡើង ។ ប្រការនេះគឺជាការសំខាន់សំរាប់កុមារី ។ នៅតាមកន្លែងជាច្រើន កុមារីត្រូវបានគេចាត់ទុកថាត្រូវតែនៅស្ងៀមស្ងាត់ និងធ្វើតាមបង្គាប់បញ្ជារ ។ ការជួយកុមារីឱ្យចេះសំរេចចិត្ត និងធ្វើតាមគំនិតរបស់នាងអាចជួយពង្រឹងជំនឿទុកចិត្ត និងលទ្ធភាពរបស់នាង ។

ពិតមែនតែអ្នកឱ្យកូនធ្វើជាអ្នកនាំមុខ តែមិនមានន័យថា អ្នកបណ្តោយឱ្យកូនធ្វើអំពើអាក្រក់ៗ ឬក៏ជំរុញកូនឱ្យធ្លាក់ចូលស្ថានភាពគ្រោះថ្នាក់នោះទេ ។ ការណែនាំរបស់អ្នក គឺជាការសំខាន់ ។ ចំណេះដឹងដែលអ្នកមានអំពីតម្រូវការភាសា និងលទ្ធភាពរបស់កូន អាចជួយឱ្យអ្នកណែនាំកូនលេងកំសាន្ត ធ្វើដូច្នេះកូននឹងរៀនសូត្របានល្អ ។

## ធ្វើឱ្យការប្រាស្រ័យទាក់ទងមានប្រយោជន៍ និងសប្បាយជក់ចិត្ត

កុមាររីករាយក្នុងការប្រាស្រ័យទាក់ទង ពេលពួកគេមានអ្វីមួយពិតៗ ធ្វើជាសញ្ញា ឬនិយាយអំពីវា និងមានមនុស្សធ្វើសញ្ញា ឬនិយាយជាមួយខ្លួន។ ព្យាយាមផ្តល់ឱកាសដល់កូនឱ្យបានច្រើនដើម្បីរៀនពីព្រឹត្តការណ៍ទាំងឡាយ លើកទឹកចិត្តកូនឱ្យធ្វើសញ្ញា និងនិយាយពីអ្វីដែលកូនបានរៀន។ ការបង្កកិច្ចសន្ទនានិយាយជាមួយកូន នឹងជួយកូនឱ្យរៀនចេះចាំបានឆាប់រហ័សជាងអ្នកសួររំលឹកកូន និងធ្វើសញ្ញា ឬនិយាយពាក្យដដែលៗ។




## ឱ្យកូនជួយធ្វើការងាររបស់អ្នក

ប្រាស្រ័យទាក់ទងជាមួយកូនពីអ្វីដែលអ្នកកំពុងធ្វើ ពេលកូនជួយធ្វើការរបស់អ្នក។ ប្រើពាក្យ ឬសញ្ញាប្រាប់កូនឱ្យជួយអ្នកធ្វើអ្វីមួយ ដូចជាប្រើកូនឱ្យយកឧបករណ៍ប្រើប្រាស់ ឬជួយអ្នកក្នុងកិច្ចការផ្សេងៗ។ កូនអ្នកនឹងផ្តោតការយកចិត្តទុកដាក់ និងចង់ប្រាស្រ័យទាក់ទងថែមទៀត ពេលគេជួយអ្នកធ្វើការងារអ្វីមួយ ដែលមានតម្លៃចំពោះអ្នកទាំងពីរ។

## ទាក់ទាញអារម្មណ៍កូន មុនពេលអ្នកប្រាស្រ័យទាក់ទង

កុមារមិនអាចស្តាប់ឮល្អត្រូវការមើលចលនាមាត់ ឬកាយវិការ ឬសញ្ញារបស់អ្នក ដើម្បីយល់ពីន័យដែលអ្នកបាននិយាយ។ កុមារបានទទួលព័ត៌មានជាច្រើនតាមរយៈការមើលឃើញលើទឹកមុខរបស់អ្នក។ ដូច្នេះជាការសំខាន់ ត្រូវចាំឱ្យកុមារមើលមកអ្នកសិន មុនពេលអ្នកចាប់ផ្តើមនិយាយ ឬធ្វើសញ្ញា។

ដើម្បីទាក់ទាញការយកចិត្តទុកដាក់ពីកុមារ ចូរខិតទៅជិតក្មេង ឬគ្រវីដៃនៅកន្លែងដែលកុមារអាចមើលឃើញ ហៅឈ្មោះកុមារ យកដៃទៅប៉ះកុមារ ឬគោះវត្ថុដែលនៅជិតឱ្យឮសម្លេងខ្លាំងៗ ធ្វើដូច្នេះកុមារបានដឹងពីភាពខ្វះមកវិញ។



**បងប្រុសរបស់*សូរិន* បានប៉ះដៃប្អូន ដើម្បីទាក់ទាញការយកចិត្តទុកដាក់ពី*សូរិន* ។**

## វិធីផ្សេងៗដែលទាក់ទាញចំណាប់អារម្មណ៍របស់កូនអ្នក

បើសិនជាកូនចាប់អារម្មណ៍លើវត្ថុអ្វីមួយ ជាងរឿងអ្នកកំពុងប្រាស្រ័យទាក់ទងជាមួយគេ អ្នកអាចទាក់ទាញចំណាប់អារម្មណ៍កូនដោយឈប់ធ្វើសកម្មភាព យកវត្ថុនោះមកដាក់ក្បែរមុខអ្នក ឬធ្វើកាយវិការ ឬធ្វើសញ្ញានៅជិតវត្ថុនោះវិញ ។

- បញ្ឈប់សកម្មភាពទាំងអស់ ។ បើសិនជាអ្នកនៅស្ងៀមឈប់ធ្វើចលនា ជាពិសេសពេលអ្នកមានវត្ថុនៅនឹងដៃ នោះកូនប្រហែលជាមើលមករកអ្នក ដើម្បីឱ្យដឹងថា ហេតុអ្វីបានជាអ្នកឈប់ ។
- យកវត្ថុដាក់ក្បែរមុខអ្នក ធ្វើដូច្នេះកូនអាចមើលមុខអ្នក និងវត្ថុក្នុងពេលតែមួយ (បើសិនជាអ្នកចង់ឱ្យកូនមើលមាត់ពេលអ្នកនិយាយ) ។
- ចង្អុលទៅ ឬធ្វើសញ្ញានៅជិតវត្ថុ (បើសិនជាអ្នកចង់ឱ្យកូនរៀនធ្វើសញ្ញាសំរាប់វត្ថុនោះ) ។




**បងស្រីរបស់*ជន*បានធ្វើសញ្ញានៅជិតល្បែងលេង**
**ដើម្បីទាក់ទាញចំណាប់អារម្មណ៍ឱ្យប្អូនមើលសញ្ញា**

ពីដំបូងអ្នកអាចពិបាកចងចាំក្នុងការទាក់ទាញចំណាប់អារម្មណ៍របស់កូនឱ្យផ្ចង់ស្មារតីយកចិត្តទុកដាក់ពេញលេញនៅមុនពេលអ្នកចាប់ផ្តើមប្រាស្រ័យទាក់ទងជាមួយគេ ។ ពេលអ្នកទម្លាប់ហាត់រៀនយូរៗទៅ អ្នកនឹងបានងាយស្រួលជាមិនខាន ។

## ធ្វើសញ្ញា ឬនិយាយទល់មុខគ្នា ត្រឹមកំរិតខ្សែចក្ខុ

បើសិនជាអ្នកលត់ជង្គង់ចុះជិតកូន (ក្នុងចម្ងាយមួយម៉ែត្រ ឬបីជំហាន) កូនអ្នកអាចយល់បានច្រើននូវអ្វីដែលអ្នកនិយាយ ឬធ្វើសញ្ញា ហើយមើលឱ្យចំភ្នែករបស់កូន ពេលអ្នកនិយាយ ឬធ្វើសញ្ញា ។

បើអាចទៅរួច សាកល្បងឱ្យមានពន្លឺថ្ងៃ ឬពន្លឺភ្លើងចាំងមកលើមុខអ្នក តែមិនមែនចាំងពីក្រោយអ្នកទេ ។ ពេលពន្លឺភ្លើងចាំងពីក្រោយអ្នក មុខនិងដៃរបស់អ្នកស្ថិតនៅក្នុងទីងងឹត ដូច្នេះវាកាន់តែពិបាកមើលថែមទៀត ។




**ម្តាយរបស់ *ម៉ារីយ៉ាណា* កំពុងលេងទះដៃជាមួយនាង ។**




បើសិនជាអ្នកនិយាយតាមធម្មតាក្នុងសម្លេងច្បាស់ៗ កូនអ្នកកាន់តែងាយយល់ពាក្យនិយាយច្រើនឡើង។ កុំស្រែកឱ្យសោះ។ ការស្រែកធ្វើឱ្យពាក្យនិយាយកាន់តែពិបាកយល់។ និយាយឱ្យខ្លី និងប្រើឃ្លាដែលងាយៗ ដើម្បីកុំឱ្យកូនស្មុគស្មាញ។ បើសិនជាអ្នកគ្មានអ្វីនៅក្នុងមាត់ ឬបាំងពីមុខបបូរមាត់របស់អ្នក ខណៈពេលអ្នកកំពុងនិយាយ វាងាយសំរាប់កូនមើលឃើញចលនាមាត់របស់អ្នក។

**បើសិនជាកូនអ្នកអាចស្តាប់ឮបន្តិចបន្តួច**

ការណែនាំខាងក្រោមនេះ អាចជួយឱ្យក្មេងស្តាប់ឮបានប្រសើរជាងមុនបន្តិច។



- ក្តោបដៃរាងកោងពីក្រោយស្លឹកត្រចៀក អាចជួយសម្លេងឮចូលក្នុងត្រចៀកបានច្រើន។
- និយាយឱ្យជិតត្រចៀកក្មេង អាចជួយឱ្យក្មេងស្តាប់ឮបានប្រសើរជាងមុន។ ប្រការនេះធ្វើឱ្យសម្លេងបានឮខ្លាំងជាងមុន និងកាត់បន្ថយសម្លេងអ៊ូអរនៅជុំវិញ។ ត្រូវចាំថា កុមារត្រូវការមើលមុខរបស់អ្នក ខណៈពេលអ្នកកំពុងនិយាយទៅរកគេ។



## ប្រើកាយវិការ ប៉ះ (ស្ទាប កេះ ឬចាប់កាន់) និងសំដែងទឹកមុខ



មនុស្សគ្រប់រូបប្រើចលនារាងកាយ ប៉ះ និងសំដែងទឹកមុខជាជំនួយឱ្យមនុស្សម្នាបានយល់នូវអ្វីដែលពួកគេចង់និយាយ ។ ជាញឹកញាប់ កុមារប្រើការប៉ះ (យកដៃទៅប៉ះ ឬកេះ) ដើម្បីប្រាស្រ័យទាក់ទងនឹងគ្នាទៅវិញទៅមក ។

កុមារមិនអាចស្តាប់ឮល្អដឹងថា ការប៉ះមានប្រយោជន៍ខ្លាំងណាស់ ។ ការប៉ះជួយបញ្ជាក់ការប្រាស្រ័យទាក់ទងនៃការយកចិត្តទុកដាក់ និងក្តីបារម្ភរបស់អ្នកដែលគ្មានវិធីណាផ្សេងអាចជំនួសបាន ។ ពេលខ្លះទៀត ចលនាកាយវិការ និងទឹកមុខអាចជំនួសកន្លែងនៃពាក្យ ឬសញ្ញា ។ នៅពេលផ្សេងទៀត វាបន្ថែមព័ត៌មានចំពោះពាក្យ និងសញ្ញា ។

ជួយកូនឱ្យបានច្រើនតាមដែលអាចធ្វើបាន ដោយប្រើចលនារាងកាយ និងទឹកមុខរបស់អ្នក ដើម្បីប្រាស្រ័យទាក់ទងជាមួយកូន ។ មុនដំបូង ព្យាយាមចំណាំរបៀបដែលអ្នកធ្លាប់ធ្វើពីមុន ។ បន្ទាប់មក ស្វែងរកវិធីបន្ថែមទៅលើអ្វីដែលអ្នកបានធ្វើរួចហើយ ។




**ទឹកមុខខឹងរបស់ *ម៉ារីយ៉ា* បានបញ្ជូនសារមួយខុសពីសំដីទន់ភ្លន់របស់គាត់ ។ បែបនេះ កុមារពិតជាយល់ច្រឡំ ។**

ព្យាយាមធ្វើឱ្យប្រាកដថា សារដែលអ្នកបញ្ជូន គួបផ្សំជាមួយចលនារាងកាយ និងទឹកមុខ គឺដូចគ្នានឹងសារដែលអ្នកនិយាយជាពាក្យ និងជាសញ្ញា ។ បើសិនជាសារនៃទឹកមុខរបស់អ្នក មិនស៊ីសង្វាក់នឹងពាក្យសម្តី នោះកូនរបស់អ្នកពិតជាមានការយល់ច្រឡំ ។

## កាត់បន្ថយអ្វីៗដែលរំខានឱ្យបានច្រើនតាមដែលអាចធ្វើបាន

ការរំខានទាំងឡាយ ដូចជាមានក្មេងដទៃទៀតលេងក្បែរកូនរបស់អ្នក វាបណ្តាលឱ្យកាន់តែពិបាកធ្វើសកម្មភាព ឬក៏មិនអាចធ្វើបាន ។ អ្នកអាចជួយបានដោយរកកន្លែងដែលមានការរំខានតិចតួច ។ ព្យាយាមបំបាត់សម្លេងរំខានដែលមិនចាំបាច់ ។ កុមារមិនអាចស្តាប់ឮល្អមានការពិបាកច្រើនក្នុងការយល់ពាក្យសម្តីដែលមនុស្សបាននិយាយរក នៅពេលបន្ទប់មានសម្លេងរំខាន ។



**ឪពុកក្មេងនេះ បិទវិទ្យុមុនពេលលេងជាមួយកូនប្រុសគាត់ ។**

## ផ្លាស់ប្តូរសកម្មភាពនានា ឱ្យសមនឹងកូនរបស់អ្នក

សកម្មភាពក្នុងសៀវភៅនេះ អាចជួយកូនអ្នករៀនប្រាស្រ័យទាក់ទង។ ប៉ុន្តែទាំងអស់នេះ គ្រាន់តែជាឧទាហរណ៍ ដែលអាចជួយកុមារឱ្យរៀនសូត្រប៉ុណ្ណោះ។ ចូរសង្កេតមើលកុមារដោយប្រុងប្រយ័ត្ន ថាតើអ្វីទៅដែលធ្វើឱ្យក្មេងចាប់អារម្មណ៍ និងចង់ប្រាស្រ័យទាក់ទង ហើយសង្កេតផងដែរនូវអ្វីដែលធ្វើឱ្យក្មេងអន់ចិត្ត និងចង់ឈប់លេង។ បន្ទាប់មក អ្នកអាចរិះគិតរកវិធីយកលំនាំតាមសកម្មភាពក្នុងសៀវភៅនេះ ធ្វើដូច្នេះសកម្មភាពទាំងនេះនឹងមានប្រសិទ្ធភាពជាងសំរាប់កូនអ្នក ហើយវាងាយស្រួល ព្រមទាំងសមស្របនៅក្នុងសកម្មភាពប្រចាំថ្ងៃនៃក្រុមគ្រួសារអ្នក។

អ្នកអាចសម្រួលសកម្មភាពទាំងនេះ ឱ្យសមនឹងលទ្ធភាពកូនអ្នក។

ឧទាហរណ៍ :-

- បើសិនជាក្មេងអាចស្តាប់ឮសម្លេងនិយាយខ្លះៗ ជួយបង្ហាត់កុមារឱ្យចេះពាក្យងាយៗ តាមរយៈការបញ្ជាក់ឡើងវិញ និងនិយាយពាក្យទាំងនេះដដែលៗ។ បន្ទាប់មក ប្រើពាក្យទាំងនោះឱ្យបានញឹកញាប់។




- បើសិនជាក្មេងមិនអាចស្តាប់ឮសម្លេងនិយាយបានល្អ ចូរបង្រៀនមនុស្សគ្រប់គ្នាឱ្យចេះសញ្ញាមួយចំនួន ដើម្បីប្រើជាមួយក្មេង។ សូមអានជំពូកទី៥ សំរាប់ព័ត៌មានអំពីការបង្រៀនភាសាសញ្ញា។




- បើសិនជាកូនអ្នកអាចស្តាប់ឮសម្លេងខ្លះៗ នៅជុំវិញខ្លួន មនុស្សគ្រប់គ្នាអាចជួយក្មេងឱ្យយកចិត្តទុកដាក់ចំពោះសម្លេងដោយចង្អុលទៅកន្លែងនោះ។



## ការជួយកូនអ្នកឱ្យចំរើនលូតលាស់

បើសិនជាអ្នកបញ្ចូលសកម្មភាពទាំងនេះ ជាចំណែកនៃការរស់នៅប្រចាំថ្ងៃនៃក្រុមគ្រួសារ វ័យកុមារភាពរបស់កូនអ្នកនឹងពោរពេញទៅដោយក្ដីសប្បាយរីករាយ និងការរៀនសូត្រ។ ខណៈពេលកុមារធំឡើង គេអាច :-

**ចូលរួមជជែកលេងជាមួយក្រុមគ្រួសារ**



**កសាងចំណងមិត្តភាពជាមួយកុមារឯទៀត**



**ទៅសាលារៀន និងរៀនពីមុខរបរមួយ**



**បានជួបជាមួយកុមារ និងមនុស្សថ្លង់ពេញវ័យ ឬមិនអាចស្ដាប់ឮល្អផ្សេងទៀត។**



**ច្រើនឆ្នាំទៅមុខ ដោយរាប់ពីឥឡូវនេះទៅ កុមារធំដឹងក្ដីឡើង គេរៀបការ និងមានគ្រួសារផ្ទាល់ខ្លួន។**

**ពួកគេនឹងមានលទ្ធភាពគាំទ្រក្រុមគ្រួសាររបស់ខ្លួន និងបានចូលរួមក្នុងសហគមន៍។**






ខណៈដែលអ្នកធ្វើសកម្មភាពនៅក្នុងសៀវភៅនេះ ចូរព្យាយាម :-

- អត់ធ្មត់។ ក្នុងមួយលើកៗ កុមារតូចៗអាចផ្ចង់ស្មារតីយកចិត្តទុកដាក់បានតែពីរ បីនាទីប៉ុណ្ណោះ។
- តាំងចិត្តឱ្យត្រជាក់។ សកម្មភាពរៀនសូត្រនឹងបានផល ដរាបណាធ្វើទៅអ្នកទាំងពីរបានសប្បាយចិត្ត។

កុំបាក់ទឹកចិត្តឱ្យសោះ។ កុំរំពឹងថាអាកប្បកិរិយារបស់កូនអ្នកនឹងផ្លាស់ប្ដូរភ្លាមៗនោះ។ កូនអ្នកនឹងបានប្រយោជន៍អ្វីមួយពីគ្រប់សកម្មភាពនីមួយៗ ទោះបីជាអ្នកមិនបានកត់សំគាល់ភ្លាមៗក៏ដោយ។